ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ១៧៧ ដនស/ប្រក.

# ប្រកាស
# ស្ដីពី
# បែបបទនិងនីតិវិធីនៃការផ្ដល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលបានសាងសង់រួចមុនច្បាប់ស្ដីពីសំណង់ចូលជាធរមាន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសំណង់
- បានឃើញព្រះរាជក្រមលេខ ០៨/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីផ្លូវថ្នល់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី
- បានឃើញអនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេ
- បានឃើញសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## **សម្រេច**

## **ជំពូកទី១**

## **បទប្បញ្ញត្តិទូទៅ**

**ប្រការ១ ._**

ប្រកាសនេះមានគោលបំណង៖

- ធានាគុណភាព សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សោភណភាពសំណង់ បរិស្ថានល្អ និងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- បង្ការនិងទប់ស្កាត់ហានិភ័យដែលបង្កឡើងដោយការប្រើប្រាស់សំណង់ដែលគ្មានគុណភាពនិងសុវត្ថិភាពសម្រាប់ការប្រើប្រាស់
- ការពារទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈដទៃទៀត
- លើកតម្លៃសេដ្ឋកិច្ចរបស់សំណង់
- គ្រប់គ្រងទិន្នន័យសំណង់ប្រកបដោយប្រសិទ្ធភាព។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅ៖

- កំណត់សមត្ថកិច្ចក្នុងការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- កំណត់បែបបទនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន
- កំណត់បទប្បញ្ញត្តិបច្ចេកទេសជាមូលដ្ឋានក្នុងការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទ ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់និងដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ដូចខាងក្រោម៖

- សំណង់ដែលគ្មានលិខិតអនុញ្ញាតសាងសង់
- សំណង់ដែលសាងសង់ខុសពីលិខិតអនុញ្ញាតសាងសង់
- សំណង់ដែលមានលិខិតអនុញ្ញាតសាងសង់ ប៉ុន្តែគ្មានវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ ឬលិខិតបិទការដ្ឋាន។

**ប្រការ៤.-**

ក្នុងរយៈពេល២(ពីរ)ឆ្នាំ ក្រោយច្បាប់ស្តីពីសំណង់ចូលជាធរមាន ម្ចាស់សំណង់ត្រូវមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់របស់ខ្លួនពីអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីសំណង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ម្ចាស់នៃសំណង់ដែលបានសាងសង់រួចមុនថ្ងៃទី២០ ខែធ្នូ ឆ្នាំ**១៩៩៧** អាចមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់របស់ខ្លួនពីអាជ្ញាធរមានសមត្ថកិច្ចបាន។

**ប្រការ៥.-**

អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ក្នុងករណីសំណង់នោះមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់និងសាធារណជន និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

ចំពោះសំណង់ដែលបានសាងសង់ក្រោយថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ វិញ្ញាបនបត្រប្រើប្រាស់សំណង់អាចផ្តល់ជូនបាន លុះត្រាតែម្ចាស់សំណង់បានបង់ប្រាក់ពិន័យអន្តរការណ៍តាមគោលការណ៍

ដែលបានកំណត់ដោយអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

**ប្រការ៦ ._**

វិញ្ញាបនបត្រប្រើប្រាស់សំណង់នៅតែមានសុពលភាព ទោះបីម្ចាស់សំណង់ត្រូវបានផ្លាស់ប្តូរក៏ដោយ។

ក្នុងករណីវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវបានព្យួរ ឬដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច សំណង់នោះមិនត្រូវបានអនុញ្ញាតឱ្យបន្តការប្រើប្រាស់ឡើយ។

រាល់ការប្តូរមុខងារប្រើប្រាស់ និង/ឬកែប្រែគ្រឿងផ្គុំនៃសំណង់ ដែលមានវិញ្ញាបនបត្រប្រើប្រាស់រួចហើយ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតប្តូរមុខងារប្រើប្រាស់ និង/ឬកែប្រែគ្រឿងផ្គុំសំណង់ពីអាជ្ញាធរមានសមត្ថកិច្ចជាមុន។

ជនណាដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅអាជីវកម្ម នូវសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសំណង់។

**ប្រការ៧ ._**

ការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវបង់កម្រៃសេវាសាធារណៈជូនរដ្ឋ។

កម្រៃសេវាក្នុងការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៨ ._**

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងប្រកាសនេះមានដូចខាងក្រោម៖

- **វិញ្ញាបនបត្រប្រើប្រាស់សំណង់** សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។
- **ម្ចាស់សំណង់** សំដៅដល់ម្ចាស់នៃសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាត ឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន។

- **អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់** សំដៅដល់មន្ត្រីជំនាញដែលបានទទួលការអនុញ្ញាតឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់។
- **ឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់** សំដៅដល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ បណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ វិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ ឬ គោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល។ ក្នុងករណីសាមីសំណើមិនមែនជាកម្មសិទ្ធិករ ត្រូវមានការព្រមព្រៀងពីម្ចាស់ដី។

## ជំពូកទី២
## សមត្ថកិច្ច

**ប្រការ៩ ..**

អាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ រួមមាន៖
- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់សំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សម្រាប់សំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ សម្រាប់សំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៣
## បែបបទនិងនីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

### ផ្នែកទី ១
### សំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

**ប្រការ១០ ..**

សំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ មានដូចខាងក្រោម៖
- ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងឯកសារបញ្ជាក់អត្តសញ្ញាណរបស់ម្ចាស់សំណង់ (ត្រូវធ្វើនីត្យានុកូលកម្មនៅអាជ្ញាធរមានសមត្ថកិច្ចឬមន្ទីរសារការី) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ ចំនួន ០៣ ច្បាប់

- សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំនួន ០៣ ច្បាប់
- សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង (ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ និងប្លង់អគ្គិភ័យ) ចំនួន ០៣ ច្បាប់
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន) ចំនួន ០៣ ច្បាប់

គំរូទម្រង់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ជាឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

**ប្រការ១១ .-**

បុគ្គលដែលអាចចុះហត្ថលេខាទទួលខុសត្រូវលើសម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង មានដូចខាងក្រោម៖

១. នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលមានវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ឬសាងសង់។

២. នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្លង់ ឬអាជ្ញាបណ្ណសាងសង់។

៣. នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង ត្រូវមានបោះត្រានិងចុះលេខវិញ្ញាបនបត្រឬលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុនដែលបានអនុវត្តការធ្វើសម្រង់ប្លង់នោះ។

សម្រាប់សំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ បុគ្គលដែលអាចចុះហត្ថលេខាទទួលខុសត្រូវលើសម្រង់ប្លង់តាមការសាងសង់ជាក់ស្តែងផងដែរ មានដូចខាងក្រោម៖

១. អ្នកវិជ្ជាជីវៈដែលមានវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ឬសាងសង់។

២. អ្នកវិជ្ជាជីវៈដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្លង់ឬអាជ្ញាបណ្ណសាងសង់។

ក្នុងករណីនេះ អ្នកវិជ្ជាជីវៈត្រូវបោះត្រានិងចុះលេខវិញ្ញាបនបត្រឬលេខអាជ្ញាបណ្ណនៅលើសម្រង់ប្លង់នោះ។

**ប្រការ១២ ._**

ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នៅការិយាល័យច្រកចេញចូលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ផ្នែកទី ២

## នីតិវិធីនៃការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ប្រការ១៣ ._**

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំ តែក្នុងករណីដែលសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវ។

**ប្រការ១៤ ._**

បន្ទាប់ពីបានទទួលសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបញ្ជូនសំណុំឯកសារស្នើសុំទៅអគ្គនាយកដ្ឋានសំណង់ ក្នុងរយៈពេលយ៉ាងយូរ ០២ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

**ប្រការ១៥ ._**

អគ្គនាយកដ្ឋានសំណង់ ដោយមាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ជាសេនាធិការ ត្រូវពិនិត្យនិងផ្តល់យោបល់លើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់។ អគ្គនាយកដ្ឋានសំណង់ត្រូវធ្វើកំណត់បង្ហាញសរុបលទ្ធផលនៃការពិនិត្យនិងផ្តល់យោបល់ និងបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យសម្រេច។

**ប្រការ១៦ ._**

ក្នុងករណីសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ពុំមានរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ផ្តល់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។ រយៈពេលនៃការចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

**ប្រការ១៧ ._**

អគ្គនាយកដ្ឋានសំណង់ ត្រូវបញ្ជូនវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀតទៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីប្រគល់ជូនម្ចាស់សំណើ។

គំរូទម្រង់នៃវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

## ផ្នែកទី៣

## នីតិវិធីក្នុងការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

**ប្រការ១៨ ._**

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មានរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត អាចចេញបង្កាន់ដៃទទួលពាក្យស្នើសុំ តែក្នុងករណីដែលសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវ។

**ប្រការ១៩ ._**

បន្ទាប់ពីបានទទួលសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារស្នើសុំនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ២(ពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

**ប្រការ២០ ..**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដោយមានការិយាល័យសំណង់ជាសេនាធិការ ត្រូវពិនិត្យនិងផ្តល់យោបល់ និងបញ្ជូនសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់រយៈពេលយ៉ាងយូរ៧(ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យសម្រេច។

ក្នុងករណីសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ពុំមានរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។ រយៈពេលនៃការចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

**ប្រការ២១ ..**

បន្ទាប់ពីបានពិនិត្យលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើសំណុំឯកសារស្នើសុំ ដូចខាងក្រោម៖

១. ផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់តាមសំណើ ក្នុងករណីពិនិត្យឃើញថា សំណង់បានគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តជាធរមាន ឬ

២. ចេញលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើសំណង់ ក្នុងករណីពិនិត្យឃើញថា សំណង់មិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តជាធរមាន។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារដែលបានសម្រេចរួច ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ០៣(បី) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារស្នើសុំ។

**ប្រការ២២ ..**

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវបញ្ជូនវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀតទៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ០៣(បី) ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីប្រគល់ជូនម្ចាស់សំណើ។

គំរូទម្រង់នៃវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

**ប្រការ២៣ .-**

ក្នុងករណីសំណង់មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងប្រកាសនេះ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបង្គាប់ឱ្យម្ចាស់សំណង់ធ្វើការកែតម្រូវ និង/ឬបំពេញបន្ថែម ឱ្យស្របតាមបទប្បញ្ញត្តិបច្ចេកទេសមុននឹងចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ក្នុងករណីមិនអាចសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់បាន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីសុំយោបល់។

រយៈពេលនៃការកែតម្រូវនិង/ឬបំពេញបន្ថែម និងរយៈពេលស្នើសុំយោបល់ទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

## ផ្នែកទី ៤

## នីតិវិធីក្នុងការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

**ប្រការ២៤ .-**

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មានរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចចេញបង្កាន់ដៃទទួលពាក្យស្នើសុំតែក្នុងករណីដែលសំណុំឯកសារនោះមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវ។

**ប្រការ២៥.-**

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ០២(ពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

**ប្រការ២៦ .-**

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យផ្តល់យោបល់ និងបញ្ជូនសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ។

ក្នុងករណីសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ពុំមានរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។ រយៈពេលនៃការចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

**ប្រការ២៧ .-**

បន្ទាប់ពីបានពិនិត្យលើសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើសំណុំឯកសារស្នើសុំ ដូចខាងក្រោម÷

១. ផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់តាមសំណើ ក្នុងករណីពិនិត្យឃើញថា សំណង់បានគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តជាធរមាន ឬ

២. ចេញលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើសំណង់ ក្នុងករណីពិនិត្យឃើញថា សំណង់មិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តជាធរមាន។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារដែលបានសម្រេចរួច ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ ០៣(បី) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារស្នើសុំ។

**ប្រការ២៨ .-**

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬលិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើ និងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀតទៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ០៣(បី) ថ្ងៃនៃថ្ងៃធ្វើការដើម្បីប្រគល់ជូនម្ចាស់សំណើ។

គំរូទម្រង់នៃវិញ្ញាបនបត្រប្រើប្រាស់សំណង់ ស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាឧបសម្ព័ន្ធទី៤នៃប្រកាសនេះ។

**ប្រការ២៩ .-**

ក្នុងករណីសំណង់មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងប្រកាសនេះ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្គាប់ឱ្យម្ចាស់សំណង់ធ្វើការកែតម្រូវនិង/ឬបំពេញបន្ថែមឱ្យស្របតាមបទប្បញ្ញត្តិបច្ចេកទេសមុននឹងចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ក្នុងករណីមិនអាចសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់បាន អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីសុំយោបល់។

ក្នុងករណីមិនអាចបានអាចផ្តល់យោបល់បាន  អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីសុំយោបល់។

រយៈពេលនៃការកែតម្រូវនិង/ឬបំពេញបន្ថែម  និងរយៈពេលស្នើសុំយោបល់តាមមាត្រានុក្រមនេះ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ឡើយ។

## ជំពូកទី៤
## បែបបទនិងនីតិវិធីនៃការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់

**ប្រការ៣០ .-**

អាជ្ញាធរមានសមត្ថកិច្ចដែលផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់  អាចសម្រេចព្យួរឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់នោះបាន  ក្នុងករណីសំណង់នោះលែងមានគុណភាពនិងសុវត្ថិភាពសម្រាប់ការប្រើប្រាស់។

**ប្រការ៣១ .-**

វិញ្ញាបនបត្រប្រើប្រាស់សំណង់នឹងត្រូវព្យួរដោយអាជ្ញាធរមានសមត្ថកិច្ច  ក្នុងករណីរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់បង្ហាញថាសំណង់នោះ ពុំមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់។

ក្នុងករណីនេះ  អាជ្ញាធរមានសមត្ថកិច្ចត្រូវបង្គាប់ជាលាយលក្ខណ៍អក្សរឱ្យម្ចាស់សំណង់ធ្វើការកែតម្រូវតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវលុបការព្យួរវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងករណីម្ចាស់សំណង់បានធ្វើការកែតម្រូវតាមការបង្គាប់របស់អាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៣២ .-**

វិញ្ញាបនបត្រប្រើប្រាស់សំណង់នឹងត្រូវដកហូតដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីណាមួយដូចខាងក្រោម៖

១. មុខងារប្រើប្រាស់សំណង់ត្រូវបានប្តូរ។

២. គ្រឿងផ្គុំសំណង់ត្រូវបានកែប្រែដោយគ្មានការអនុញ្ញាត។

៣. សំណង់មានសភាពគ្រោះថ្នាក់ តាមការសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។

## ជំពូកទី៥
## របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់

**ប្រការ៣៣ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវសម្រេចផ្តល់ ព្យួរ ឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ដោយផ្អែកលើរបាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវធ្វើដោយមន្ត្រីត្រួតពិនិត្យសំណង់ ឬក្រុមហ៊ុនដែលមានវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវមានហត្ថលេខាទទួលខុសត្រូវរបស់៖

១. មន្ត្រីត្រួតពិនិត្យសំណង់ ឬ

២. នាយកបច្ចេកទេសក្រុមហ៊ុនដែលមានវិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ឬ

៣. នាយកបច្ចេកទេសក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវមានបោះត្រា និងចុះលេខវិញ្ញាបនបត្រ ឬលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុននោះ។

គំរូទម្រង់របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជាឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

**ប្រការ៣៤ .-**

មន្ត្រីត្រួតពិនិត្យសំណង់ ដែលមានសមត្ថកិច្ចចុះអនុវត្តការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ដែលជាកម្មវត្ថុនៃការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ រួមមាន៖

- មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសំណង់ ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មន្ត្រីជំនាញនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំពោះសំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- មន្ត្រីជំនាញនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ចំពោះសំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៦

## បទប្បញ្ញត្តិបច្ចេកទេស

**ប្រការ៣៥ ._**

វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្តល់ជូនបានសម្រាប់សំណង់ដែលសាងសង់នៅលើដីដែលបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី ស្របតាមប្លង់សុរិយោដី និងប្លង់ហេដ្ឋារចនាសម្ព័ន្ធ។

**ប្រការ៣៦ ._**

វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្តល់ជូនបានសម្រាប់សំណង់ដែលអនុលោមតាមបទប្បញ្ញត្តិរៀបចំដែនដី និងនគរូបនីយកម្មដូចមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តដូចខាងក្រោម៖

ក. ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ ចំពោះសំណង់ដែលបានចាប់ផ្តើមសាងសង់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៧ ដល់ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥។

ខ. ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន បទប្បញ្ញត្តិ គោលការណ៍ និងសេចក្តីណែនាំជាធរមាន ចំពោះសំណង់ដែលបានចាប់ផ្តើមសាងសង់នៅក្រោយថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ និងបញ្ចប់ការសាងសង់មុនច្បាប់ស្តីពីសំណង់ចូលជាធរមាននៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩។

**ប្រការ៣៧ ._**

វិញ្ញាបនបត្រប្រើប្រាស់សំណង់ អាចផ្តល់ជូនបានសម្រាប់សំណង់ដែលអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដូចខាងក្រោម÷

- គ្រឿងផ្គុំសំណង់អាចទ្ររាល់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់របស់សំណង់
- សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ដែលអាចធានាគុណភាពសំណង់ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ ស្របតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ឬស្តង់ដាកម្ពុជាដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដាជាតិ
- មានសុវត្ថិភាពអគ្គិភ័យ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ។

## ជំពូកទី៧

## ការប្តឹងតវ៉ា

**ប្រការ៣៨ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយការសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់ ការព្យួរ ឬការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ មានសិទ្ធិប្តឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ច ឬទៅតុលាការតាមនីតិវិធីជាធរមាន។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ៣៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤០ .-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ជា សុផារ៉ា

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  “**ដើម្បីជូនជ្រាប**”
- ដូចប្រការ៤០ “**ដើម្បីអនុវត្ត**”
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

*ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ ០៧៧.ដនស/ប្រក. ចុះថ្ងៃទី...០៦.....ខែ...ធ្នូ.........ឆ្នាំ២០១៩....ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់*
*វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

***គំរូទម្រង់***
*សម្រាប់សមត្ថកិច្ចរបស់ក្រសួង*

## ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ.......................... ភេទ...... សញ្ជាតិ.......... ថ្ងៃខែឆ្នាំកំណើត................ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ........................ និងប្រពន្ធ/ ប្តីឈ្មោះ................... សញ្ជាតិ........ ថ្ងៃខែឆ្នាំកំណើត............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ................. មានទីលំនៅបច្ចុប្បន្នផ្ទះលេខ....... ផ្លូវ........ ភូមិ........... ឃុំ/ សង្កាត់................ ក្រុង/ ស្រុក/ ខណ្ឌ............... រាជធានី/ ខេត្ត................ តំណាងឱ្យក្រុមហ៊ុន................................ ចុះបញ្ជីលេខ............. ចុះថ្ងៃទី.... ខែ........ ឆ្នាំ......... ទីស្នាក់ការស្ថិតនៅអគារលេខ.................. ភូមិ............... ឃុំ/ សង្កាត់...................... ក្រុង/ ស្រុក/ ខណ្ឌ.................. រាជធានី/ ខេត្ត...................... ។

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**តាមរយៈ**÷ - ប្រធានច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់

**កម្មវត្ថុ** ÷ សំណើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាអនុញ្ញាតផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដល់ខ្ញុំបាទ/ នាងខ្ញុំ ដែលបានសាងសង់រួចរាល់ កាលពីថ្ងៃទី.... ខែ...... ឆ្នាំ........ ជាប្រភេទសំណង់.......................... សាងសង់អំពី................. កំពស់............. ម៉ែត្រ ស្មើនឹង........... ជាន់ ផ្ទៃក្រឡាសំណង់សរុប...................... ម² មានទីតាំងស្ថិតនៅលើដីឡូត៍លេខ............... ផ្លូវលេខ............. ភូមិ................ ឃុំ/ សង្កាត់....................... ក្រុង/ ស្រុក/ ខណ្ឌ................ រាជធានី/ ខេត្ត.................... ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដល់ខ្ញុំបាទ/ នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/ នាងខ្ញុំ។

**សូមគោរពជូនភ្ជាប់ជាមួយនូវ÷**

១. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណង់ ឬអ្នកតំណាង ចំនួន ០៣ ច្បាប់

២. ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

៣. លិខិតប្រគល់សិទ្ធិរបស់ក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

| | |
|---|---|
| ៤. ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ | ចំនួន ០៣ ច្បាប់ |
| ៥. សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | ចំនួន ០៣ ច្បាប់ |
| ៦. សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង | ចំនួន ០៣ ច្បាប់ |
| ៧. របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់( បើមាន) | ចំនួន ០៣ ច្បាប់ |
| ៨. ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់( បើមាន) | ចំនួន ០៣ ច្បាប់ |
| ៩. ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់( បើមាន) | ចំនួន ០៣ ច្បាប់ |
| ១០. ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់( បើមាន) | ចំនួន ០៣ ច្បាប់ |
| ១១. ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន) | ចំនួន ០៣ ច្បាប់ |
| ១២. ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន) | ចំនួន ០៣ ច្បាប់ |

ថ្ងៃ.................... ខែ.......... ឆ្នាំ................... ព.ស. .........

ធ្វើនៅ............. ថ្ងៃទី...... ខែ.......... ឆ្នាំ.........

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកស្នើសុំ**

<u>**សម្គាល់៖**</u> រាល់ឯកសារថតចម្លង ត្រូវធ្វើនីត្យានុកូលកម្ម នៅអាជ្ញាធរមានសមត្ថកិច្ច ឬមន្ទីរសារការី។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

***គំរូទម្រង់***

*សម្រាប់សមត្ថកិច្ចរបស់រដ្ឋបាលរាជធានី/ខេត្ត*

## ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ........................ភេទ...... សញ្ជាតិ.........ថ្ងៃខែឆ្នាំកំណើត............... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ...................... និងប្រពន្ធ/ប្តីឈ្មោះ.................. សញ្ជាតិ........ថ្ងៃខែឆ្នាំកំណើត............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ................ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......ផ្លូវ........ភូមិ..........ឃុំ/ សង្កាត់................ក្រុង/ ស្រុក/ ខណ្ឌ.............. រាជធានី/ ខេត្ត................ តំណាងឱ្យក្រុមហ៊ុន.............................. ចុះបញ្ជីលេខ............. ចុះថ្ងៃទី.... ខែ........ឆ្នាំ......... ទីស្នាក់ការស្ថិតនៅអគារលេខ.................. ភូមិ...............ឃុំ/ សង្កាត់..................... ក្រុង/ ស្រុក/ ខណ្ឌ.................រាជធានី/ ខេត្ត.....................។

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី/ខេត្ត...............**

**តាមរយៈ**÷ - ប្រធានអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី/ ខេត្ត...............

- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី/ ខេត្ត...............

**កម្មវត្ថុ** ÷ សំណើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាផ្តល់ វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដល់ខ្ញុំបាទ/ នាងខ្ញុំ ដែលបានសាងសង់រួចរាល់ កាលពីថ្ងៃទី....ខែ......ឆ្នាំ........ ជាប្រភេទសំណង់.........................សាងសង់អំពី................ កំពស់............ ម៉ែត្រ ស្មើនឹង...........ជាន់ ផ្ទៃក្រឡាសំណង់សរុប.........................ម² មានទីតាំងស្ថិតនៅលើដីឡូត៍លេខ............. ផ្លូវលេខ............. ភូមិ................ ឃុំ/ សង្កាត់...................... ក្រុង/ ស្រុក/ ខណ្ឌ............... រាជធានី/ ខេត្ត..................។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាពិនិត្យនិង សម្រេច ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/ នាងខ្ញុំ។

<u>**សូមគោរពជូនភ្ជាប់ជាមួយនូវ÷**</u>

១. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណង់ ឬអ្នកតំណាង ចំនួន ០៣ ច្បាប់

២. ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

| | |
|---|---|
| ៣. លិខិតប្រគល់សិទ្ធិរបស់ក្រុមហ៊ុន (ករណីក្រុមហ៊ុន) | ចំនួន ០៣ ច្បាប់ |
| ៤. ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ | ចំនួន ០៣ ច្បាប់ |
| ៥. សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | ចំនួន ០៣ ច្បាប់ |
| ៦. សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង | ចំនួន ០៣ ច្បាប់ |
| ៧. របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ៨. ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ៩. ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ១០. ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ១១. ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន) | ចំនួន ០៣ ច្បាប់ |
| ១២. ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន) | ចំនួន ០៣ ច្បាប់ |

ថ្ងៃ.................... ខែ.......... ឆ្នាំ.................... ព.ស. .........

ធ្វើនៅ.............. ថ្ងៃទី...... ខែ.......... ឆ្នាំ.........

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកស្នើសុំ**

<u>**បញ្ជាក់:**</u> រាល់ឯកសារថតចម្លង ត្រូវធ្វើនីត្យានុកូលកម្ម នៅអាជ្ញាធរមានសមត្ថកិច្ច ឬមន្ទីរសារការី។

*ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ..១៧៧ ដនសស/ប្រក ចុះថ្ងៃទី..០៦......ខែ..ធ្នូ.........ឆ្នាំ២០១៩.....ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់ វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់មុនច្បាប់ស្តីពីសំណង់ចូលជាធរមាន*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

***គំរូទម្រង់***

*សម្រាប់សមត្ថកិច្ចរបស់រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ*

## <u>ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់</u>

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ.......................... ភេទ...... សញ្ជាតិ.......... ថ្ងៃខែឆ្នាំកំណើត................ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ....................... និងប្រពន្ធ/ ប្ដីឈ្មោះ.................. សញ្ជាតិ........ ថ្ងៃខែឆ្នាំកំណើត............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ................. មានទីលំនៅបច្ចុប្បន្នផ្ទះលេខ....... ផ្លូវ........ ភូមិ........... ឃុំ/ សង្កាត់................ ក្រុង/ ស្រុក/ ខណ្ឌ............... រាជធានី/ ខេត្ត................ តំណាងឱ្យក្រុមហ៊ុន............................... ចុះបញ្ជីលេខ............. ចុះថ្ងៃទី.... ខែ........ ឆ្នាំ......... ទីស្នាក់ការស្ថិតនៅអគារលេខ.................. ភូមិ................ ឃុំ/ សង្កាត់...................... ក្រុង/ ស្រុក/ ខណ្ឌ..................រាជធានី/ ខេត្ត......................។

**សូមគោរពជូន**

**លោក/លោកស្រីអភិបាល នៃគណៈអភិបាលក្រុង/ស្រុក/ខណ្ឌ............**

**តាមរយៈ**÷ - ប្រធានការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង/ ស្រុក/ ខណ្ឌ...........

- ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង/ ស្រុក/ ខណ្ឌ...........

**កម្មវត្ថុ** ÷ សំណើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់មុនច្បាប់ស្តីពីសំណង់ចូលជាធរមាន

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **លោក/លោកស្រីអភិបាល** មេត្តាផ្ដល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដល់ខ្ញុំបាទ/ នាងខ្ញុំ ដែលបានសាងសង់រួចរាល់ កាលពីថ្ងៃទី.... ខែ...... ឆ្នាំ........ ជាប្រភេទសំណង់......................... សាងសង់អំពី................. កំពស់............ ម៉ែត្រ ស្មើនឹង........... ជាន់ ផ្ទៃក្រឡាសំណង់សរុប.......................ម² មានទីតាំងស្ថិតនៅលើដីឡូត៍លេខ.............. ផ្លូវលេខ............. ភូមិ................ ឃុំ/ សង្កាត់...................... ក្រុង/ ស្រុក/ ខណ្ឌ............... រាជធានី/ ខេត្ត..................។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **លោក/លោកស្រីអភិបាល** មេត្តាពិនិត្យនិងសម្រេច ដោយក្ដីអនុគ្រោះ។

សូម **លោក/លោកស្រីអភិបាល** មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/ នាងខ្ញុំ។

<u>*សូមគោរពជូនភ្ជាប់ជាមួយនូវ÷*</u>

១. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណង់ ឬអ្នកតំណាង ចំនួន ០៣ ច្បាប់

២. ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

| | |
|---|---|
| ៣. លិខិតប្រគល់សិទ្ធិរបស់ក្រុមហ៊ុន (ករណីក្រុមហ៊ុន) | ចំនួន ០៣ ច្បាប់ |
| ៤. ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ | ចំនួន ០៣ ច្បាប់ |
| ៥. សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | ចំនួន ០៣ ច្បាប់ |
| ៦. សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង | ចំនួន ០៣ ច្បាប់ |
| ៧. របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ៨. ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ៩. ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ១០. ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ១១. ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន) | ចំនួន ០៣ ច្បាប់ |
